**OAKLAND UNIFIED SCHOOL DISTRICT**
*Community Schools, Thriving Students*

**OFFICE OF THE SUPERINTENDENT**
ការិយាល័យនៃអគ្គនាយកនៃសង្កាត់សាលារៀនអូកឡិនដ៍

សូមគោរពជូនប្រជាសហគមន៍នៃសង្កាត់សាលារៀនអូកឡិនដ៍,

ថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិកទាំងឡាយរបស់សង្កាត់ កំពុងយកចិត្តទុកដាក់ខ្ពស់ចំពោះវីរុសកូរ៉ូណា (COVID-19) និងព័ត៌មានមកពីដៃគូសុខភាពសាធារណៈរបស់យើង នៅថ្នាក់សហព័ន្ធ ថ្នាក់រដ្ឋ និងថ្នាក់មូលដ្ឋាន។ យើងខ្ញុំចង់ចែករំលែកព័ត៌មានថ្មីបំផុតមួយចំនួន ដែលបានមកពីបុគ្គលិកបំរើសេវាកម្មសុខភាពរបស់យើង ព្រមទាំងផែនការសម្រាប់ការដែលអាចកើតរីករាលដាលនៃមេរោគកូរ៉ូណានៅក្នុងសហគមន៍របស់យើង។

នៅថ្ងៃអង្គារទី 25 ខែកុម្ភៈ មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជម្ងឺឆ្លង (CDC) បានផ្តល់ព័ត៌មានថ្មីៗស្តីពីស្ថានភាពបច្ចុប្បន្ននៃមេរោគ COVID-19 ហើយថាតើគួរចាត់វិធានការអ្វីខ្លះដើម្បីឱ្យដំណើរការឆ្ពោះទៅមុខបាន។ **សូមកត់សម្គាល់ថា យោងទៅតាមនាយកដ្ឋានសុខភាពសាធារណៈប្រចាំខោណ្ឌីអាឡាមីដា (ACPHD) យើងខ្ញុំពុំទាន់មានការបញ្ជាក់ថាមានករណីឆ្លងមេរោគនេះ នៅក្នុងតំបន់អាឡាមីដានាពេលនេះទេ។**

ខណៈដែលហានិភ័យសុខភាពដល់សាធារណជនទូទៅនៅក្នុងរដ្ឋកាលីហ្វូនញ៉ានៃយើង នៅមានកំរិតទាបនៅឡើយនោះ មជ្ឈមណ្ឌល CDC ថ្មីៗនេះ បានបញ្ជាក់ជូនថា មេរោគកូរ៉ូណា មុខជាជិតនឹងចាប់ផ្តើមរីករាលដាលនៅក្នុងសហគមន៍នានានៅសហរដ្ឋអាមេរិកជាមិនខាន ហើយយើងត្រូវចាប់ផ្តើមត្រៀមពីពេលឥឡូវនេះហើយ។ យើងខ្ញុំកំពុងធ្វើការជាមួយដៃគូមូលដ្ឋាន និងជាមួយមន្ត្រីសុខាភិបាល ដើម្បីបង្កើតពិធីការសម្រាប់សាលារៀននានា ក្នុងព្រឹត្តការណ៍ដែលមេរោគ COVID-19 អាចឆ្លងរីករាលដាលនៅក្នុងទីក្រុងអូកឡិនដ៍។ ព័ត៌មានថែមទៀត នឹងត្រូវបានចែករំលែកនៅពេលដែលផែនការនេះ ត្រូវបានរៀបចំឡើង។ នៅក្នុងពេលនេះ ព័ត៌មានថ្មីៗស្តីអំពីមេរោគកូរ៉ូណា គឺមានដាក់ជូននៅលើគេហទំព័រនៃមជ្ឈមណ្ឌល CDC និងនាយកដ្ឋានសុខភាព ACPHD ក៏ដូចជាគេហទំព័រផ្ទាល់របស់យើងផងដែរ នៅ www.ousd.org/coronavirus។ ដោយសារស្ថានភាពពិភពលោកកំពុងប្រែប្រួលយ៉ាងលឿនយ៉ាងនេះ យើងនឹងបន្តវាយតម្លៃលើវិធានការ និងការសកម្មភាពរបស់យើងជារៀងរាល់ថ្ងៃ។

របាយការណ៍របស់មជ្ឈមណ្ឌល CDC បានបង្ហាញថា ការឆ្លងរាលដាលនៃមេរោគ COVID-19 ពីមនុស្សទៅមនុស្ស ហាក់ដូចជាកើតឡើងភាគច្រើន តាមរយៈការចម្លងមេរោគតាមផ្លូវដង្ហើម។ បុគ្គលិកសុខភាព និងសុខុមាលភាពរបស់យើង ណែនាំតាមវិធានការនានាដូចតទៅនេះ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគតាមផ្លូវដង្ហើមទាំងអស់នេះ៖

- លាងដៃអ្នកឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកយ៉ាងហោចណាស់ ឱ្យបាន 20 វិនាទី។ ប្រសិនបើសាប៊ូ និងទឹកមិនអាចរកបាន សូមប្រើទឹកលាងដៃដែលមានជាតិអាល់កុល។
- ចៀសវាងប៉ះពាល់ភ្នែក ច្រមុះ និងមាត់របស់អ្នក ដោយដៃដែលពុំបានលាងសំអាតជាមុន។
- ចៀសវាងនៅក្បែរមនុស្សដែលមានជម្ងឺឈឺថ្កាត់។
- លាងសំអាត និងសម្លាប់មេរោគដែលនៅជាប់លើវត្ថុ និងនៅលើផ្ទៃផ្សេងៗដែលត្រូវបានប៉ះជាញឹកញាប់។
- ចាក់វ៉ាក់សាំងការពារជំងឺផ្តាសាយឱ្យបានជារៀងរាល់ឆ្នាំ។
- សម្រាកនៅផ្ទះ នៅពេលណាអ្នកមានជម្ងឺឈឺថ្កាត់។
- ខ្ទប់មាត់របស់អ្នកនៅពេលក្អក ឬកណ្តាស់ ដោយក្រដាស់ជូតមាត់ បន្ទាប់មកបោះវាចោលក្នុងធុងសម្រាម។
- មនុស្សណាដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ និង/ឬ មនុស្សណាដែលមានរោគសញ្ញាធ្ងន់ធ្ងរ គួរត្រូវបានទៅពិនិត្យសុខភាពដោយអ្នកជំនាញវេជ្ជសាស្ត្រ។

សូមជ្រាបថា យើងខ្ញុំទាក់ទងជាប្រចាំជាមួយនឹងនាយកដ្ឋានសុខភាព ACPHD និងការិយាល័យអប់រំប្រចាំខោណ្ឌីអាឡាមីដា ហើយនឹងផ្តល់ដំណឹងថ្មីបំផុតជូនលោកអ្នកជ្រាប នៅពេលណាយើងខ្ញុំទទួលបាននូវព័ត៌មានថែមទៀត ហើយនិងនៅពេលណាផែនការក្រៅថែមទៀតសម្រាប់សាលារៀននានារបស់យើង ត្រូវបានលើកយកមកពិភាក្សាគ្នា។

នៅពេលណាលើកយកមកនិយាយអំពីបញ្ហាធ្ងន់ធ្ងរទាំងនេះជាមួយនឹងកូនៗរបស់លោកអ្នក ជាពិសេសនៅពេលដែលមានប្រព័ន្ធផ្សព្វផ្សាយជាច្រើន ដែលអាចផ្សាយបំភ្លើសហួសការពិត ដូចជារឿងវីរុសកូរ៉ូណានេះជាដើម អាចធ្វើឱ្យក្មេងៗមានការភ័យខ្លាច។ ការដឹងពីវិធីល្អបំផុតក្នុងការនិយាយអំពីប្រធានបទដ៏រសើបនេះជាមួយកុមារ អាចជួយឱ្យពួកគេមានអារម្មណ៍ធូរស្រាលជាធម្មតា ហើយនិងធ្វើឱ្យជីវិតរបស់លោកអ្នកមានលក្ខណៈងាយស្រួលផងដែរ។ សម្រាប់ការណែនាំអំពីវិធីដោះស្រាយការសន្ទនាបែបនេះ នោះសូមចូលអានក្នុង គេហទំព័រនេះ ដែលក្នុងនោះមានព័ត៌មានដែលលោកអ្នកគិតថាមានប្រយោជន៍។

យើងខ្ញុំដឹងថា ភាពរឹងមាំ និងការរួបរួមសាមគ្គីគ្នារបស់សិស្ស ក្រុមគ្រួសារ និងបុគ្គលិកនៃយើង នឹងជួយឱ្យយើងឆ្លងផុតពេលព្រួយបារម្ភខ្លាំងលើសុខភាពប្រកបដោយជោគជ័យ។ តាងនាមអោយថ្នាក់ដឹកនាំរបស់សង្កាត់ និងក្រុមការងារបំរើសេវាសុខភាពនៃសង្កាត់សាលារៀនអូកឡិនដ៍ នាងខ្ញុំសូមថ្លែងអំណរអរគុណចំពោះភាពជាដៃគូរបស់លោកអ្នក៕

ដោយក្តីគោរពស្មោះអំពីនាងខ្ញុំ,

Kyla Johnson-Trammell
អគ្គនាយកនៃសង្កាត់សាលារៀនអូកឡិនដ៍